**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១១៨/០១៨/២០០៦

ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦

**សេចក្តីសម្រេច**

លេខ : ០៨៩/០១៦/២០០៦ កបធ.ច

ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ
- បានឃើញលិខិតលេខ សឆ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់តំណាងរាស្ត្រ ចំនួន ១៤ រូប ស្នើសូមពិនិត្យមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដើម្បីធ្វើការប្រកាសថា មិនស្រប នឹងរដ្ឋធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ វេលាម៉ោង ០៩ : ៣០ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា កម្មវត្ថុនៃលិខិតរបស់តំណាងរាស្ត្រ ចំនួន ១៤ រូប មានខ្លឹមសារបង្កាប់បញ្ហា ពីព្រោះប្រើពាក្យថា " *សូមពិនិត្យមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដើម្បីធ្វើការប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ* "

- យល់ឃើញថា ការយោងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញនៅក្នុងលិខិតលេខ សធ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦របស់តំណាងរាស្ត្រ ចំនួន ១៤ រូប មិនត្រឹមត្រូវ ពីព្រោះច្បាប់ស្តីពីលក្ខន្តិកៈតំណាង-រាស្ត្រ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ រួចទៅហើយ
- យល់ឃើញថា ខ្លឹមសារនៃលិខិតលេខ សធ/០៦/៩៩ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ២០០៦ របស់តំណាង-រាស្ត្រ ចំនួន ១៤ រូប បានថ្លែងថា "*...យើងខ្ញុំបានឃើញនូវចម្លើយរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៦ ពាក់ព័ន្ធនឹងមាត្រា ៩ នៃច្បាប់នេះរួចហើយ ដោយក្រុមប្រឹក្សាធម្មនុញ្ញបានឆ្លើយបញ្ជាក់ថា មាត្រា ៩ នោះពុំមានអធម្មនុញ្ញភាពទេ។ យើងខ្ញុំមានការសោកស្តាយ ដែលក្រុមប្រឹក្សាពុំបានពិនិត្យនូវខ្លឹមសារនៃមាត្រា៨ ផង ដែលមាត្រានេះបង្ហាញមិនអាចប្រកែកបាននូវអធម្មនុញ្ញភាព ។ព្រោះវាមានលក្ខណៈងាយយល់ជាង*" ។ ជាគោលការណ៍ និង តាមយុត្តិសាស្ត្ររបស់ខ្លួនតាំងពីឆ្នាំ១៩៩៨ មក ក្រុមប្រឹក្សាធម្មនុញ្ញមិនអាចយកបញ្ហាណាមួយមកពិនិត្យដោយខ្លួនឯងបានឡើយ លុះត្រាតែមានការស្នើសុំពីឥស្សរជន ដូចមានចែងក្នុងមាត្រា ១៤០ ថ្មី មាត្រា ១៤១ ថ្មីវាក្យខ័ណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញ ឬ ប្រជារាស្ត្រដូចមានចែងក្នុងមាត្រា ១៤១ ថ្មីវាក្យខ័ណ្ឌទី២នៃរដ្ឋធម្មនុញ្ញ ទើបក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ
- យល់ឃើញថា ថ្វីបើមានបញ្ហាខ្វះ ក្រុមប្រឹក្សាធម្មនុញ្ញអាចយកសំណើរបស់តំណាងរាស្ត្រ ចំនួន ១៤ រូប មកពិនិត្យនៅក្នុងក្របខ័ណ្ឌនៃមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨
- យល់ឃើញថា អភ័យឯកសិទ្ធិសភា មិនមែនជាឯកសិទ្ធិរបស់តំណាងរាស្ត្រទេ ប៉ុន្តែជាការធានាមួយផ្តល់ជូនរដ្ឋសភា ដើម្បីឱ្យការប្រព្រឹត្តទៅរបស់ខ្លួនមានប្រសិទ្ធភាពល្អ និង គ្មានឧបសគ្គ ។ ផ្តើមចេញពីអភ័យ-ឯកសិទ្ធិផ្តល់ជូនរដ្ឋសភានេះ សមាជិកម្នាក់ៗរបស់រដ្ឋសភាមិនត្រូវបានគេចោទប្រកាន់ ឃាត់ខ្លួន ចាប់ខ្លួន ឬ ឃុំខ្លួនជាដាច់ខាត ដោយសារការបញ្ចេញមតិ ឬ ការបោះឆ្នោតទាំងឡាយក្នុងពេលបំពេញមុខងាររបស់ខ្លួននៅរដ្ឋសភា ។ ប៉ុន្តែ ការរួចផុតពីការទទួលខុសត្រូវនេះ ក៏មានព្រំដែនកំណត់ដែរ គឺអំពើ ឬ សំដីខុសឆ្គងទាំងឡាយរបស់សមាជិករដ្ឋសភានឹងអាចត្រូវបានផ្តន្ទាទោសផ្នែកវិន័យដោយរដ្ឋសភា ដូចមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា
- យល់ឃើញថា ក្រៅពីពេលបំពេញមុខងាររបស់ខ្លួននៅរដ្ឋសភា តំណាងរាស្ត្រម្នាក់ៗនឹងអាចត្រូវបានគេចោទប្រកាន់ ឃាត់ខ្លួន ចាប់ខ្លួន ឬ ឃុំខ្លួនទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬ គណៈ-កម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើស

ព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ជាបន្ទាន់ដើម្បីសម្រេច ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័ត

- យល់ឃើញថា ការសម្រេចព្យួរអភ័យឯកសិទ្ធិសភាពីតំណាងរាស្ត្រ ឬ ការសម្រេចប្រគល់ឱ្យវិញនូវអភ័យឯកសិទ្ធិសភាដល់តំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់រដ្ឋសភា
- យល់ឃើញថា បទបញ្ញត្តិក្នុងចំណុចទី ១ និង ចំណុចទី ២ នៃមាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មានចែងអំពីអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រ ដែលតាមការពិតជាអភ័យឯកសិទ្ធិរបស់រដ្ឋសភាទេ ។

## សម្រេច

**មាត្រា ១.-** ផ្អែកតាមមូលបទខាងលើ មាត្រា ៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៦/០២៥ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០០៦ ពុំមានអធម្មនុញ្ញភាពទេ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៦

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន